**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្ដីពី ការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រាមួយ .-**

មាត្រា១ នៃអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា ១ .- ថ្មី**

ត្រូវបានបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ ដែលមានផ្ទៃដីទំហំ ៥.៥២០ (ប្រាំពាន់ប្រាំរយម្ភៃ) ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា (Datum: WGS1984) ដូចខាងក្រោម៖

| និយាមកាគោល | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ID | X | Y | ID | X | Y | ID | X | Y |
| 1 | 347071 | 1173105 | 14 | 342840 | 1175820 | 27 | 346230 | 1184119 |
| 2 | 345195 | 1173309 | 15 | 342828 | 1176296 | 28 | 346967 | 1184663 |
| 3 | 345180 | 1173543 | 16 | 342043 | 1176531 | 29 | 347396 | 1184085 |
| 4 | 344794 | 1173589 | 17 | 342030 | 1176999 | 30 | 348326 | 1183188 |
| 5 | 344485 | 1173919 | 18 | 341023 | 1176979 | 31 | 348065 | 1182181 |
| 6 | 344033 | 1174016 | 19 | 340527 | 1177512 | 32 | 349582 | 1180444 |
| 7 | 344041 | 1174671 | 20 | 340686 | 1178160 | 33 | 349055 | 1179496 |
| 8 | 343536 | 1174668 | 21 | 341093 | 1178093 | 34 | 348416 | 1179362 |
| 9 | 343534 | 1174854 | 22 | 342509 | 1180561 | 35 | 348100 | 1177460 |
| 10 | 343028 | 1174849 | 23 | 342594 | 1181140 | 36 | 347292 | 1176702 |
| 11 | 343026 | 1175088 | 24 | 343139 | 1181531 | 37 | 347470 | 1175348 |
| 12 | 342618 | 1175086 | 25 | 344899 | 1183694 | 38 | 346662 | 1174667 |
| 13 | 342548 | 1175814 | 26 | 345725 | 1184135 | | | |

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




និយាមកាគោល

| ID | X_Coord | Y_Coord |
|---|---|---|
| 1 | 347071 | 1173105 |
| 2 | 345195 | 1173309 |
| 3 | 345180 | 1173543 |
| 4 | 344794 | 1173589 |
| 5 | 344485 | 1173919 |
| 6 | 344033 | 1174016 |
| 7 | 344041 | 1174671 |
| 8 | 343536 | 1174668 |
| 9 | 343534 | 1174854 |
| 10 | 343028 | 1174849 |
| 11 | 343026 | 1175088 |
| 12 | 342618 | 1175086 |
| 13 | 342548 | 1175814 |
| 14 | 342840 | 1175820 |
| 15 | 342828 | 1176296 |
| 16 | 342043 | 1176531 |
| 17 | 342030 | 1176999 |
| 18 | 341023 | 1176979 |
| 19 | 340527 | 1177512 |
| 20 | 340686 | 1178160 |
| 21 | 341093 | 1178093 |
| 22 | 342509 | 1180561 |
| 23 | 342594 | 1181140 |
| 24 | 343139 | 1181531 |
| 25 | 344899 | 1183694 |
| 26 | 345725 | 1184135 |
| 27 | 346230 | 1184119 |
| 28 | 346967 | 1184663 |
| 29 | 347396 | 1184085 |
| 30 | 348326 | 1183188 |
| 31 | 348065 | 1182181 |
| 32 | 349582 | 1180444 |
| 33 | 349055 | 1179496 |
| 34 | 348416 | 1179362 |
| 35 | 348100 | 1177460 |
| 36 | 347292 | 1176702 |
| 37 | 347470 | 1175348 |
| 38 | 346662 | 1174667 |